# ស្វែងយល់ខ្លះៗអំពីរាជធានីសម័យអង្គរ (ភាគ២)

## រាជធានីមហេន្ទ្របវ៌ត (ភ្នំគូលេន)

ក្នុងអត្ថបទភាគ១ ខ្ញុំបានលើកមកបង្ហាញត្រួសៗអំពីការចាប់ផ្តើមនូវសម័យអង្គរ និងការស្ថាបនារាជធានីនានាដោយក្សត្រផ្សេងៗ។ ការចាប់ផ្តើមស្ថាបនារាជធានីគោលសម្រាប់ការគ្រប់គ្រងរាជ្យ និងទឹកដីជាលើកដំបូងគឺនៅលើខ្នងភ្នំគូលេនសព្វថ្ងៃ ដែលនាសម័យនោះត្រូវបានគេប្រសិទ្ធិនាមហៅថា មហេន្ទ្របវ៌ត មានន័យថា ភ្នំដែលទេពជាធំនៃព្រះឥន្ទ្រ ក្នុងនាមជាព្រះសិវៈ។ ការស្ថាបនារាជធានីនេះឡើង ក្រោយព្រះបាទជ័យវរ្ម័នទី២ បានតស៊ូធ្វើសង្គ្រាមយ៉ាងសកម្មគ្រប់ទីកន្លែង ដើម្បីរួបរួមអាណាចក្រដែលបានបែងចែកជាក្រុងតូចៗដឹកនាំដោយស្តេចត្រាញ់ មេទ័ព និងមន្ត្រីធំៗ នៅភាគខាងត្បូង ខាងជើង និងខាងលិចនៃបឹងទន្លេសាប។

មុននិងយល់អំពីរាជធានីមហេន្ទ្របវ៌ត ខ្ញុំសូមលើកយកជីវប្រវត្តិ និងសកម្មភាពរបស់ព្រះបាទជ័យវរ្ម័នទី២មកបង្ហាញបន្តិច។ ចំពោះបញ្ហានេះ មានអ្នកស្រាវជ្រាវជនជាតិបារាំងពីរនាក់បានធ្វើការសិក្សានិងធ្វើអំណះអំណាងរៀងៗខ្លួន ពិសេសលោក G. Cœdès និង លោក Claude Jacques។ ក្រោយមក លោក Michael Vickery (ជនជាតិអាមេរិកាំង) បានធ្វើការវិភាគគំនិតយោបល់ជនជាតិបារាំងទាំង២នេះ។ ការសិក្សាអំពីជីវប្រវត្តិ និងសកម្មភាពរបស់ព្រះបាទជ័យវរ្ម័នទី២ គឺពឹងផ្អែកលើសិលាចារឹកសំខាន់ៗមួយចំនួន។

ក្នុងសៀវភៅប្រវត្តិសាស្ត្ររបស់លោកសឺដេស (The Indianized States)[1] និងអត្ថបទស្តីពីរាជធានីរបស់ព្រះបាទជ័យវរ្ម័នទី២[2]គាត់បានធ្វើការសង្ខេបពីសម័យកាលរបស់ព្រះបាទជ័យវរ្ម័នទី២ ថា៖ ស្តេចអង្គនេះប្រហែលយាងមកពីជ្វាប្រហែលនៅរវាងឆ្នាំ៨០២ និងចាប់ផ្តើមបោះទីតាំងរាជធានីរបស់ព្រះអង្គនៅ ***ឥន្ទ្របុរៈ*** គឺប្រហែលជាបន្ទាយព្រៃនគរ ខាងកើតខេត្តកំពង់ចាម។ ក្រោយមកទ្រង់បានផ្លាស់ទៅតំបន់មួយខាងជើងបឹងទន្លេសាប គឺទឹកដី ***ករបុរៈ***។ នៅពេលពួកគេបានទៅដល់ស្រុកភាគខាងកើត មហាក្សត្របានប្រទានដីនិងភូមិមួយដែលហៅថា ***កុតិ*** (មិនមែនក្រុងឬធានីទេ)ទៅអោយគ្រួសាររាជបុព្វជិតនោះ។

---

[1] G. Cœdès, (1968)

[2] G. Cœdès, (1928:113-123)

អត្ថបទដោយ៖ សុខ កែវ សុវណ្ណារ៉ា

ក្រោយមក ព្រះអង្គបានគ្រងរាជ្យនៅទីក្រុង ***ហរិហរាល័យ*** សព្វថ្ងៃគេស្គាល់ថារលួស ដែលមានចំងាយប្រហែល១៨គ.មភាគអាគ្នេយ៍អង្គរ។ បន្ទាប់ពីនោះមក ព្រះអង្គបាន យាងទៅកសាងរាជធានី ***អមរេន្ទ្របុរៈ*** ដែលទីតាំងនេះប្រហែលជានៅភាគពាយ័ព្យ បាត់) (ដំបង។ ក្រោយមក ព្រះបាទជ័យវរ្ម័នទី២ បានយាងទៅ ***មហេន្ទ្របវ៌ត*** ដែលគេជឿថា ភ្នំគូលេន ទីនោះជាកន្លែងប្រារព្ធពិធីសាសនាមួយដើម្បី អោយព្រះអង្គក្លាយទៅជា ចក្រវាតិន ដែលពិធីនេះរៀបចំដោយព្រាហ្មណ៍ម្នាក់ឈ្មោះថា ***ហិរណ្យទាម*** ដែលមកពីជនបទ។ បន្ទាប់ពីនោះមក ព្រះអង្គប្រហែលជាបានបញ្ចប់រាជ្យនៅ ***ហរិហរាល័យ*** រវាងគ.ស៨៥០។ (សូមមើលផែនទីរូបលេខ១)

ចំណែកលោក ខ្លូដ ហ្សាក[3] បានធ្វើសេចក្តីសន្និដ្ឋានខុសពីលោកសឺដេសបន្តិច គឺះ គាត់សរសេរថា មិនយូរប៉ុន្មានក្រោយពីយាងមកដល់កម្ពុជាវិញ រវាងគស៧៧០ ព្រះបាទ. ជ័យវរ្ម័នទី២ បានដឹកនាំនៅ***ឥន្ទ្របុរៈ***(បន្ទាយព្រៃនគរ) និងប្រហែលជានៅ ***វ្យាធបុរៈ***(បាភ្នំ) ផងដែរ។ ក្រោយមកនៅរវាងគ.ស៧៧០ដល់៧៨០ ទ្រង់បានគ្រប់គ្រងអាណាចក្រ ***សម្ភុបុរៈ*** (ក្រចេះ)។ នៅរវាងគ.ស៧៨០ និង៨០២ ប្រហែលព្រះអង្គបានវាយដណ្តើមយក ***ភវបុរៈ*** (សំបូរព្រៃគុក)។ តពីនោះមក ព្រះអង្គបានកាន់កាប់ ***អនិន្ទិតបុរៈ***(ប្រាសាទអកយំ) ស្ថិតនៅកណ្តាលតំបន់អង្គរ រួចកាន់កាប់ ***កុតិ*** នៅខាងកើតអង្គរ និង ***ហរិហរាល័យ*** ហើយនិង ***អមរេន្ទ្របុរៈ***(បាត់ដំបង)។ (សូមមើលផែនទីរូបលេខ២) លោក ក្លូតហ្សាហ្គ មានសំយោគថ្មីខុសគ្នាបន្តិចចំពោះពត៌មានស្តីអំពី ព្រះបាទជ័យវរ្ម័នទី២ គឺជាសំយោគមួយដែលពឹងផ្អែកទៅលើសិលាចារឹក K.583 ពាក់ព័ន្ធនិងព្រះបាទជ័យវរ្ម័នទី២ និងបុត្រារបស់ទ្រង់ឈ្មោះ ឥន្ទ្រយុធ ក្នុងឆ្នាំ៧៩០។

នេះជាគំនិតរបស់អ្នកស្រាវជ្រាវទាំង២ ហើយលោក វិក្គ៏រី[4]បានសំយោគលើសម្មតិកម្មទាំង២នេះ ហើយស្នើឡើងថា៖ ព្រះបាទជ័យវរ្ម័នទី២ ជាអ្នកដឹកនាំ ឬជាស្តេច (១) ត្រាញ់តំបន់ណាមួយ ប្រហែលនៅភាគអាគ្នេយ៍កម្ពុជា អាចជា វ្យាធបុរៈ ឬឥន្ទ្របុរៈ ឬទាំងពីរតំបន់ក្នុងឆ្នាំ៧៧០។ (២) ប្រហែលនៅឆ្នាំ៧៨០ ព្រះបាទជ័យវរ្ម័នទី២បានទទួលអោយ

[3] Claude Jacque, (1972:205-220)

[4] Michael Vickery, (2001-2002)

ឡើងគ្រងរាជ្យនៅសម្ភុបុរៈ (ក្រចេះ) ជាតំបន់ដែលមានរាជវង្សក្សត្រីដឹកនាំផ្ទាល់នៅទីនោះ ហើយប្រហែលព្រះអង្គបានរៀបអភិសេកជាមួយក្សត្រីមួយអង្គនៅសម្ភុបុរៈ។ (៣) ក្នុងឆ្នាំ៧៩០ ព្រះអង្គ និងបុត្រាព្រះនាម ឥន្ទ្រយុធ បានច្បាំងប្រឆាំងចាមដោយទទួលបានជោគជ័យ (ពេលនោះមជ្ឈមណ្ឌលកណ្ដាលចម្ប៉ានៅ ប៉ានទូរ៉ង់ហ្គា ឬជិតកម្ពុជាខាងត្បូង)។ ក្នុងកំឡុងពីឆ្នាំ៧៨០ដល់៨០២ ព្រះបាទជ័យវរ្ម័នទី២បានកាន់កាប់តំបន់ជាច្រើន (៤) នៅភាគខាងជើងកម្ពុជា រួមទាំងបាត់ដំបង និងសៀមរាបផង។ (៥) នៅឆ្នាំ៨០២ ឬក្រោយនេះ ព្រះអង្គបានប្រារព្ធពិធីនៅលើភ្នំមហេន្ទ្របវ៌ត ដើម្បីអោយខ្លួនព្រះអង្គក្លាយជាស្ដេចអស្ចារ្យ ជា ***ចក្រវតីន***។ ក្រោយមករាជធានីព្រះអង្គក៏តាំងនៅហរិហរាល័យ (រលួស)។

ទាំងនេះជាការវែកញែករបស់អ្នកទាំង៣អំពីដំណើរនិងសកម្មភាពរបស់ព្រះបាទជ័យវរ្ម័នទី២ ពិសេសព្រឹត្តិការណ៍ឆ្នាំ៨០២គ.ស។

***ការពិតយើងមិនដឹងថា តើមានព្រឹត្តិការណ៍អ្វីកើតឡើងនៅឆ្នាំ៨០២នោះទេ ព្រោះយើងពុំមានសិលាចារឹកណាមួយដែលចារនៅក្នុងឆ្នាំនោះ ហើយរៀបរាប់អំពីព្រឹត្តិការណ៍កើតឡើងទាំងនោះទេ។ អ្វីដែលយើងដឹង គឺបានមកពីសិលាចារឹកដែលចារក្រោយព្រឹត្តិការណ៍ជាង២៥០ឆ្នាំ។***

ពត៌មានស្ដីអំពីការតាំងរាជធានីនៅមហេន្ទ្របវ៌ត ទាំងកិច្ចពិធី កម្រតេងជគតតរាជ (លទ្ធិទេវរាជ) ធ្វើនៅឆ្នាំ ៨០២គ.ស ជាពត៌មានដែលបានមកពីសិលាចារឹកស្ដុកកក់ធំ K.235[5] អាចចារក្នុងឆ្នាំ១០៥២គ.ស (៩៧៤ស.ក) រាជ្យព្រះបាទឧទ័យទិត្យវរ្ម័នទី២ (១០៥០គ.សដល់១០៦៦គ.ស) គឺជាង២៥០ក្រោយព្រឹត្តិការណ៍នោះ។ ក្នុងអត្ថបទជាភាសាខ្មែរ បន្ទាត់ទី៥៦[6] បង្ហាញថា ***មន វ្រះ បាទ បរមេស្វរៈ ប្រតិស្ឋា កម្រតេង ជគត ត រាជ នៅ នគរ ស្រី មាហេន្ទ្របវ៌ត*** មានន័យថា ព្រះបាទបរមេស្វរៈ (មរណៈនាមរបស់ព្រះបាទជ័យវរ្ម័នទី២) បានស្ថាបនានិងធ្វើពិធី កម្រតេង ជគត ត រាជនៅនគរស្រីមហេន្ទ្របវ៌ត (ភ្នំគូលេន)។ ក្នុងបន្ទាត់ទី៨០ បង្ហាញថា ព្រះអង្គសុគតនៅនគរហរិហរាល័យ ( ***វ្រះ បាទ បរមេស្វរៈ ស្វ***

---

[5] Louis Finot, (1915:)

[6] Chhany Sak. Humphry, (2005:93)

***គ្គ៌ត នៅ នគរ ហរិហរាលយ)***។ ឃ្លាទាំង២នេះ បង្ហាញថាព្រះអង្គបានទៅបង្កើតនគរមហេន្ទ្របវ៌ត និងចុងក្រោយយាងទៅសុគតនៅឯនគរហរិហរាល័យវិញ។

តើរាជធានីមហេន្ទ្របវ៌តនៅទីណា? និងមានរចនាសម្ព័ន្ធអ្វីខ្លះ?

ពិតណាស់ តាមរយៈសិលាចារឹកស្តុកកក់ធំ គេបានស្គាល់ពីឈ្មោះរាជធានីមហេន្ទ្របវ៌ត ដែលជាទីកន្លែងធ្វើពិធីពិសិដ្ឋរបស់ព្រះបាទជ័យវរ្ម័នទី២។ អ្នកស្រាវជ្រាវមុនៗបានអោយគំនិតខុសៗគ្នាលើទីតាំងរបស់មហេន្ទ្របវ៌តនេះ។ លោក Aymnier ដែលបានធ្វើការនៅលើខ្នងភ្នំគូលេន តែដោយសារអវត្តមាននៃប្រាសាទសំខាន់នៅទីនោះ លោកបានគិតថា មហេន្ទ្របវ៌តគឺស្ថិតនៅក្រោមជើងភ្នំ ឬប្រាសាទបេងមាលា[7] និងលោក Loius Finot ថានៅប្រាសាទព្រះខ័ន។[8] ក្រោយការរកឃើញដោយ លោក Goloubew នូវប្រាង្គប្រាសាទជាច្រើនធ្វើអំពីឥដ្ឋ ដែលមានក្បាច់ចម្លាក់ក្នុងចន្លោះ សិល្បៈខ្មែរសម័យដើម និងសិល្បៈសម័យព្រះបាទឥន្ទ្រវរ្ម័ន ទើបគេសម្រេចរួមគ្នាមួយថា ***មហេន្ទ្របវ៌តគឺជាភ្នំគូលេន*** (រូបលេខ៣)។ គេដឹងទៀតថា មានប្រាសាទជាច្រើនត្រូវបានស្ថាបនានៅលើភ្នំនោះ ហើយប្រាសាទដែលគេចាប់អារម្មណ៍និងយល់ថាជាទីតាំងធ្វើពិធី គឺប្រាសាទ ***គ្រួសព្រះអារាមរោងចិន ឬអារាមរោងចិន*** (រូបលេខ៤)។[9] ក្រោយការសិក្សារបស់លោក Stern បង្ហាញថាមានប្រាសាទសាងនៅក្នុងតំបន់នោះជាង៣០។[10] ប៉ុន្តែ គេមិនបានដឹងពិតប្រាកដអំពីការរៀបចំក្រុងនៅទីនោះទេ ហើយការសិក្សាលើរចនាសម្ព័ន្ធនានារបស់រាជធានីនេះក៏មិនមានដែរ។ ក្រោយឆ្នាំ២០១៨ ដោយមានការស្រាវជ្រាវបន្ថែមរបស់ក្រុមមូលនិធិបុរាណវិទ្យា និងការអភិវឌ្ឍន៍កម្មវិធីភ្នំគូលេន រួមនិងអាជ្ញាធរជាតិអប្សរា គេបានជួបប្រទះនូវរចនាសម្ព័ន្ធកំពែង១នៅលើខ្នងភ្នំគូលេន ហៅថា **បន្ទាយ ឬផ្ទះគូចារ្យ**។[11] បន្ទាយនេះមានទីតាំងនៅខាងជើងប្រាសាទគ្រួសអារាមរោងចិន ដែលមានបណ្តោយកើតលិចប្រហែល

[7] E. Aymonier, (1904:471),

[8] G. Cœdès, (1928:113-123),

[9] Lawrence Palmer Briggs, (1951:88)

[10] Philippe Stern, (1938:150-174)

[11] សាឃឿន សក្កា និងទាំងអស់, (២០១៨)

អត្ថបទដោយ៖ សុខ កែវ សុវណ្ណារ៉ា

៦០០ម៉ែត្រ និងទទឹងប្រហែល៤០០ម៉ែត្រ ហើយមានសំណង់ឥដ្ឋមួយចំនួននៅចំកណ្ដាលបន្ទាយនោះ (រូបលេខ២៥)។[12] គេបានធ្វើកំណាយនៅតាមកន្លែងមួយចំនួន (រូបលេខ២៦) ដោយបានប្រទះឃើញនូវរចនាសម្ព័ន្ធសំណង់ផ្សេងៗ ពិសេសនៅផ្នែកខាងកើត ធ្វើអំពីឥដ្ឋ (រូបលេខ២៧ និងលេខ២៨) និងមានសំណល់គ្រឿងដែលជាគ្រឿងប្រក់ដំបូលសំណង់ឥដ្ឋ ថ្ម និងឈើ។ ជាបណ្ដោះអាសន្ន គេបានស្នើថា ទីតាំងដែលគេហៅថា បន្ទាយ នេះអាចជអតីតរាជវាំងរបស់ព្រះបាទជ័យវរ្ម័នទី២នៅលើខ្នងភ្នំ មហេន្ទ្របវ៌ត។ ប៉ុន្តែ រចនាសម្ព័ន្ធផ្សេងៗរបស់រាជវាំងនេះនៅមិនទាន់បានសិក្សាលម្អិតនៅឡើយទេ។

ជាសង្ខេប យើងអាចដឹងថា រាជធានីមហេន្ទ្របវ៌ត គឺស្ថិតនៅលើខ្នងភ្នំគូលេន ហើយអាចមានរាជវាំងមួយសម្រាប់ការគង់នៅរបស់ព្រះបាទជ័យវរ្ម័នទី២ មុនការយាងចុះមកហរិហរាល័យ។ ក្រោយការរកឃើញកំពែងដែលអ្នកស្រុកហៅថា បន្ទាយឬផ្ទះគូចារ្យ ធ្វើអោយអ្នកស្រាវជ្រាវកាន់តែមានពត្ទឹលើព័តមានរាជវាំងចាស់នៅមហេន្ទ្របវ៌តនេះ។ កំណាយស្រាវជ្រាវបែបបុរាណវិទ្យាក៏ត្រូវបានអនុវត្តជាបណ្ដើរៗ ហើយគេអាចនិងយល់ច្បាស់អំពីរចនាសម្ព័ន្ធរាជធានី និងរាជវាំងនេះនាពេលអនាគត។

[12] សុខា បញ្ញា (២០១៩:១៣)




រូបលេខ១៖ សកម្មភាពរបស់ព្រះបាទជ័យវរ្ម័នទី២តាមគំនិតលោក ហ្សាក់ សឺដេស




រូបលេខ២៖ សកម្មភាពរបស់ព្រះបាទជ័យវរ្ម័នទី២តាមគំនិតលោក ខ្លូត ហ្សាក់

អត្ថបទដោយ៖ សុខ កែវ សុវណ្ណារ៉ា




រូបលេខ១៣៖ ការតាំងរាជធានីនៅមហេន្ទ្របវ៌ត (ភ្នំគូលេន)

AMS



រូបលេខ១៤៖ គ្រឹះប្រាសាទគ្រួសអារាមរោងចិន (ទីតាំងធ្វើលទ្ធិទេវរាជ)



រូបលេខ២៥៖ ស្នាកស្នាមបន្ទាយ រូបថតស្កេនដោយ LIDAR (ប្រភពអាជ្ញាធរអប្សរា)




រូបលេខ២៦៖ រណ្តៅកំណាយនៅបន្ទាយ (ប្រភពរបាយការណ៍ សាឃឿន សក្កា ២០១៨)

អត្ថបទដោយ៖ សុខ កែវ សុវណ្ណារ៉ា



រូបលេខ៧៖ រណ្ដៅកំណាយនៅបន្ទាយ (រូបថត សុខា បញ្ញា)



រូបលេខ៨៖ រណ្ដៅកំណាយនៅបន្ទាយ (រូបថត សុខា បញ្ញា)

# ឯកសារយោង


សាឃឿន សក្ដា និងទាំងអស់, (២០១៨), *របាយការណ៍បឋមស្ដីពីកំណាយបុរាណដ្ឋានបន្ទាយ ឬហៅថាផ្ទះគូចារ្យ*, សៀមរាប។

សុខា បញ្ញា (២០១៥), *សិក្សាពីរចនាសម្ព័ន្ធបន្ទាយនៅលើភ្នំគូលែន*, សារណាបញ្ចប់បរិញ្ញាប័ត្របុរាណវិទ្យា, ភ្នំពេញ។

Chhany Sak. Humphry, (2005:93), *The Sdok Kak Thom Inscription*, Buddhist Institute.

Claude Jacque, (1972:205-220), *La Carrière de Jayavarman II*, BEFEO, Tome LIX, Paris.

E. Aymonier, (1904:471), *Le Cambodge*, Tome III, Paris.

G. Cœdès, (1928:113-123), *Les Capitales de Jayavarman II*, BEFEO, Tome XXVIII, Paris.

G. Cœdès, (1968), *The Indianised States of Southeast Asia*, East-West Centre Press, Honolulu.

Lawrence Palmer Briggs, (1951:88), *The Ancient Khmer Empire*, Transactions of the American Philosophical Society, 4 (1).

Louis Finot, (1915:), *L´Inscription de Sdok Kak Thom*, BEFEO, Tome XV(2), Paris, pp.53-106.

Michael Vickery, *History of Cambodia*, Summery of Lectures given at the Faculty of Archaeology, Phnom Penh, 2001-2002.

Philippe Stern, (1938:150-174), *Travaux executes au Phnom Kulen, 15 avril-20 mai 1936*, BEFEO, Tome 38.


អត្ថបទដោយ៖ សុខ កែវ សុវណ្ណារ៉ា